# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌
លេខ ២៨០.ព្រទ.៦១៦០-៩៤

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
## សូមជម្រាបមក

លោក ប្រធានតុលាការខេត្ត ក្រុង
លោក ប្រធានព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង

*សូមជ្រាប។*

**កម្មវត្ថុ:** អំពីទម្រង់បែបបទនៃការសុំដោះលែងទណ្ឌិត ដោយមានមលក្ខខ័ណ្ឌ ។
**យោង:** ព្រះរាជសារចុះថ្ងៃទី១៥-១១-៩៣ របស់ព្រះករុណាព្រះបាទនរោត្តមសីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ។
សេចក្តីណែនាំលេខ ៥០៧ រ.ប-៩៣ ចុះថ្ងៃទី១៣-០៩-៩៣ របស់ក្រសួងយុត្តិធម៌ ។

ខ្ញុំសូមជម្រាបលោកថា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គទ្រង់បានផ្ញើព្រះរាជសារណែនាំ ចុះថ្ងៃទី១៤-១១-៩៣ ស្តីពីការសុំលើកលែងទោស និងបន្ថយទោសអោយទណ្ឌិតដែលមានខ្លឹមសារដូចតទៅៈ

១-ការសុំលើកលែងទោស ឬបន្ថយទោសឲ្យទណ្ឌិតទាំង ២ភេទ អាចប្រព្រឹត្តទៅបាន២ដង ក្នុងមួយឆ្នាំ គឺក្នុងព្រះរាជពិធីបុណ្យតាំងតុ និងក្នុឱកាសបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ។

២-ការសុំលើកលែងទោសបានតែចំពោះទណ្ឌិតដែលត្រូវតុលាការផ្តន្ទាទោសមិនធ្ងន់ធ្ងរហើយ កែប្រែខ្លួនបានល្អនៅក្នុងពន្ធនាគារ ។ចំណែឯទណ្ឌិតដែលត្រូវតុលាការផ្តន្ទាទោស ធ្ងន់ធ្ងរ គប្បីស្នើសុំមកត្រឹមការបន្ថយទោសឲ្យបានហើយ ។

កន្លងមកក្រសួងយុត្តិធម៌ពិនិត្យឃើញថា ការសុំលើកលែងទោស និងបន្ថយទោសអោយទណ្ឌិតក៏ដូចជាការសុំដោះលែងទណ្ឌិត ដោយមានលក្ខខ័ណ្ឌតែងតែធ្វើសំណើជូនមកក្រសួងយុត្តិធម៌ចំពោះទណ្ឌិតទូទៅមិនថាទណ្ឌិតជាប់ទោសធ្ងន់ធ្ងរ ឬ ស្រាលឡើយ ។

អំណើះតទៅ ដើម្បីអនុវត្តឲ្យបានស្របទៅតាមខ្លឹមសារនៃព្រះរាជសារខាងលើ សូមលោកធ្វើលិខិតស្នើសុំដោះលែងទណ្ឌិតដោយមានលក្ខខ័ណ្ឌ តែចំពោះទណ្ឌិតណាដែលបានប្រព្រឹត្តបទល្មើសមិនធ្ងន់ធ្ងរ និងទទួលរងទោសក្នុងពន្ធនាគារបាន ២ភាគ៣ នៃទោសកំណត់ក្នុងសាលក្រម និងទណ្ឌិតណាដែលមានជម្ងឺធ្ងន់ធ្ងរមិនអាចទុកនៅពន្ធនាគារបាន ។

ចំពោះទណ្ឌិតណា ដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ដូចជាបទសម្លាប់មនុស្សដោយចេតនា សម្លាប់មនុស្សដោយចតនាគិតទុកជាមុន រំលោភសេពសន្ថវៈរួចសម្លាប់ ប្លន់ប្រដាប់អាវុធ ឬប្រព្រឹត្តបទល្មើសបន្តបន្ទប់មិនរាងចាលពិសេសគឺបទឧក្រិដ្ឋ គួរគប្បីពិនិត្យឲ្យបានច្បាស់លាស់មិនគួរធ្វើសំណើសុំមកក្រសួងយុត្តិធម៌ សុំការដោះលែងដោយមានលក្ខខ័ណ្ឌនោះឡើយ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្នួន**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ប្រធានតុលាការកំពូល
-អគ្គព្រះរាជអជ្ញាអមតុលាការកំពូល (ដើម្បីជ្រាប)
-ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង (ដើម្បីអនុវត្ត)
-ប្រធានតុលាការខេត្ត ក្រុង (ឯកសារ)